# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ រាជរដ្ឋាភិបាលខ្មែរទាក់ទងបញ្ហាសិទ្ធិមនុស្ស

**Website: www.hoksavann.org**

ថ្ងៃទី២៣ ធ្នូ ២០០៩



ជារៀងរាល់ឆ្នាំ របាយការណ៍របស់តំណាងលោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា, អង្គការអន្តរជាតិនានាទាំងក្នុងនិងក្រៅប្រទេស បានចោទរាជរដ្ឋាភិបាលខ្មែរថា បានរំលោភសិទ្ធិមនុស្សខាងការបញ្ចេញមតិ, បានដេញប្រជាពលរដ្ឋពីលំនៅរបស់ខ្លួន ។ រាល់ការចោទប្រកាន់បានត្រូវរាជរដ្ឋាភិបាលខ្មែរបដិសេធជានិច្ច ។ តទៅនេះ យើងគួរពិនិត្យមើលសកម្មភាពរបស់រាជរដ្ឋាភិបាលខ្មែរ តើមានការពិតបែបណា ?

សារពត៌មាន វិទ្យុ ទូរទស្សន៍ នៅប្រទេសកម្ពុជា គេទទួលស្គាល់ថាមានចំនួនច្រើនពិតមែន ប៉ុន្តែចំនួនច្រើននោះ តើមានសិទ្ធិសរសេរ មានសិទ្ធិនិយាយតាមបំណងរបស់ខ្លួនឬទេ ? នៅសម័យបោះឆ្នោត វិទ្យុឯកជនមួយបានត្រូវក្រសួងពត៌មានបិទ ដោយចោទថានិយាយការមិនពិត មានគំនិតគាំទ្រគណបក្សប្រឆាំង។ សារពត៌មានពីរបីដែលគាំទ្រគណបក្សប្រឆាំង បានត្រូវទទួលរងគ្រោះ ដោយត្រូវគេលួចបាញ់សម្លាប់ បានត្រូវគេប្តឹងឡើងតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារ និងបង់ផាកពិន័យ ។ ចំណែកសារពត៌មាន វិទ្យុ និងទូរទស្សន៍ភាគច្រើន ដែលបានសុខរហូតមកទល់ពេលនេះ ដោយសារតែសរសេរនិងនិយាយហែអើជាមួយរាជរដ្ឋាភិបាល ទោះបីឃើញខុសក៏មិនហ៊ាននិយាយ ព្រោះខ្លាច (ភយាគតិ) គេចោទថាបរិហាកេរ្តិ៍ ។ ដូច្នេះតើគេអាចចាត់ទុកថា ប្រទេសកម្ពុជាមានសេរីភាពខាងការបញ្ចេញមតិឬទេ ?

ការបញ្ចេញមតិតាមរយៈការធ្វើកូដកម្ម បាតុកម្មវិញ សុំច្បាប់មិនឲ្យ ។ បើហ៊ានធ្វើត្រូវគេបង្ក្រាបដោយដំបងឆក់ ដោយចោទថា បាតុកម្ម កូដកម្មគ្មានច្បាប់អនុញ្ញាត ។ ដូច្នេះតើឲ្យប្រជាពលរដ្ឋចេញផ្លូវណា ដើម្បីអាចបញ្ចេញមតិរបស់ខ្លួន បើអាជ្ញាធរខ្មែរខ្ទប់គ្រប់ច្រកបែបនេះ ។ ក្នុងពេលថ្មីៗនេះ សភាបានអនុម័តច្បាប់ធ្វើបាតុកម្ម គួរឲ្យអស់សំណើចត្រង់មាត្រាដែលកំណត់ទីកន្លែងនិងចំនួនមនុស្សធ្វើបាតុកម្ម ។ តើច្បាប់ធ្វើបាតុកម្មក្នុងពិភពលោក គេមានចែងដូច្នេះឬទេ ? ។ ឧបមាថាប្រជាពលរដ្ឋសុំច្បាប់ធ្វើបាតុកម្មមានចំនួនមនុស្ស១,០០០នាក់ តែច្បាប់អនុញ្ញាតឲ្យធ្វើតែចំនួន៣០០នាក់ ដូច្នេះនៅសល់៧០០នាក់គ្មានសិទ្ធិធ្វើ ។ រាជរដ្ឋាភិបាលមានបំណងបិទបាំងការពិត មិនចង់ឲ្យគេដឹងថា ប្រជាពលរដ្ឋប្រឆាំង ។ រាជរដ្ឋាភិបាលនៅតែមិនអាចបិទមិនឲ្យធ្វើបាតុកម្មបាន ទោះបីច្បាប់នេះបានអនុម័តហើយក៏ដោយ ដោយយកមូលហេតុថា នាំឲ្យស្មុះចរាចរ នាំឲ្យខូចរបៀបរៀបរយសណ្តាប់ធ្នាប់ក្នុងសង្គម ។ តើច្បាប់មានលក្ខណៈបែបនេះ អាចចាត់ទុកថាជាច្បាប់បើកសិទ្ធិឲ្យប្រជាពលរដ្ឋបញ្ចេញមតិតាមរយៈធ្វើបាតុកម្មឬទេ ?

ការដេញប្រជាពលរដ្ឋពីលំនៅរបស់ខ្លួន រហូតមានកន្លែងខ្លះត្រូវប៉ូលិសបាញ់ត្រូវរបួសនិងស្លាប់ នៅពេលដែលប្រជាពលរដ្ឋពុំព្រមចេញដោយសារគ្មានសំណង ឬសំណងតិចតួចមិនត្រូវនឹងតម្លៃទីផ្សារ តើអំពើបែបនេះចាត់ទុកថាជាអំពើរំលោភសិទ្ធិមនុស្សឬទេ ? អំពើរំលោភយកដីរបស់ប្រជាពលរដ្ឋនេះ ឈ្មោះថារំលោភច្បាប់រដ្ឋធម្មនុញ្ញជាច្បាប់កំពូលត្រង់មាត្រា៤៤ចែងថា «កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យនិងយុត្តិធម៌» ។

អង្គការក្រៅរដ្ឋាភិបាល អង្គការសិទ្ធិមនុស្សនានានៃពិភពលោក បានស្នើសុំឲ្យរដ្ឋាភិបាលខ្មែរ ស្នើសុំទៅព្រះមហាក្សត្រខ្មែរលើកលែងទោសលោកហង្ស-ចក្រា ចាងហ្វាងសារពត៌មានខ្មែរម្ចាស់ស្រុក និងលើកលែងទោសលោកមឿង-សុនប្រធានសមាគមទ្រទ្រង់អរិយធម៌ខ្មែរ ត្រូវរាជរដ្ឋាភិបាលខ្មែរធ្វើព្រងើយកន្តើយគ្មានយកចិត្តទុកដាក់អ្វីឡើយ ។ ផ្ទុយទៅវិញបែរជាប្រញាប់ប្រញាល់ឲ្យព្រះមហាក្សត្រខ្មែរលើកលែងទោសលោកស៊ីវ៉ារ៉ាក់-ចូធីពង្ស ជាជាតិថៃដែលខ្លួនចោទថា ជាចារកិច្ចរបស់ថៃ ហើយកាត់ទោសឲ្យជាប់គុក៧ឆ្នាំ ។ ភាពតានតឹងកើតឡើងកាន់តែខ្លាំង បន្ទាប់ពីរាជរដ្ឋាភិបាលទទួលលោកថាក់ស៊ីន អតីតនាយករដ្ឋមន្ត្រីថៃ ដែលត្រូវគេទម្លាក់ពីតំណែងឲ្យចូលមកប្រទេសកម្ពុជា ហើយតែងតាំងជាទីប្រឹក្សាសេដ្ឋកិច្ច ។ ផលវិបាក, ថៃបានដកឯកអគ្គរាជទូតចេញពីប្រទេសកម្ពុជា ឯរាជរដ្ឋាភិបាលខ្មែរខ្លាចគេដេញរាជទូតខ្មែរនៅបាងកក ក៏សំរេចដកក្រោយគេ ។ រឿងចាប់ស៊ីវ៉ារ៉ាក់ដាក់គុក ដោយចោទថាជាចារកិច្ចថៃឃ្លាំមើលជើងយន្តហោះដែលដឹកលោកថាក់ស៊ីន ហើយលើកលែងទោសវិញក្តី ការដកទូតក្តី រហូតលិខិតសម្ងាត់ដែលក្រសួងការបរទេសថៃធ្វើទៅអាភីស៊ិតនាយករដ្ឋមន្ត្រីថៃបច្ចុប្បន្ន ថានឹងអាចធ្វើចម្បាំងជាមួយខ្មែរក្តី ទាហានឈុតខ្មៅថៃចេះតែលួចបាញ់សម្លាប់ប្រជាពលរដ្ឋខ្មែរនៅតាមព្រំប្រទល់ដែនខ្មែរក្តី ដោយសារការសង់សឹកនិងកំហឹងរបស់ថៃ បន្ទាប់ពីរាជរដ្ឋាភិបាលខ្មែរទទួលលោកថាក់ស៊ីនឲ្យធ្វើជាទីប្រឹក្សាសេដ្ឋកិច្ច ដែលជាជនមានទោសត្រូវគេតាមចាប់យកមកដាក់ពន្ធនាគារ ។ បានសេចក្តីថា លាក់ចោរដែលគេកំពុងតាមចាប់ ។ រឿងគេទម្លាក់លោកថាក់ស៊ីនស្របច្បាប់ក្តីមិនស្របច្បាប់ក្តី ជារឿងផ្ទៃក្នុងរបស់គេ យើងខាងក្រៅមានសិទ្ធិត្រឹមតែទទួលស្គាល់រាជរដ្ឋាភិបាលនោះ ឬមិនទទួលស្គាល់ប៉ុណ្ណោះ ។ ប៉ុន្តែចាប់ពីទម្លាក់លោកថាក់ស៊ីនមក ប្រទេសនានាក្នុងពិភពលោក

រួមទាំងអង្គការសហប្រជាជាតិផង នៅតែទទួលស្គាល់រាជរដ្ឋាភិបាលថៃបច្ចុប្បន្ននេះ មានតែខ្មែរម្នាក់ឯងគត់ទទួលស្គាល់លោកថាក់ស៊ីន អតីតនាយករដ្ឋមន្ត្រីដែលគេទម្លាក់ពីតំណែង ព្រមទាំងតែងតាំងឲ្យធ្វើជាទីប្រឹក្សាសេដ្ឋកិច្ចផង ។ មួយទៀត ការតែងតាំងឲ្យលោកថាក់ស៊ីនធ្វើជាទីប្រឹក្សានេះ សង្ស័យថាជាខែលបាំងមុខ ព្រោះខ្វះអីគេចេះបញ្ហាសេដ្ឋកិច្ច តែអាចថាជារឿងនយោបាយចង់ឲ្យខ្មែរមានរឿងជាមួយថៃកាន់តែខ្លាំងឡើង តាមការរុញច្រានពីលោកតាឥសូរទិសខាងកើត ហើយមិនឲ្យខ្មែរនឹកឃើញបញ្ហាទឹកដីទិសខាងកើតផង ។ ដូច្នេះភាពតានតឹងកើតឡើងរវាងខ្មែរនិងថៃពេលនេះ គឺមានមូលហេតុពីការទទួលលោកថាក់ស៊ីនឲ្យធ្វើជាទីប្រឹក្សាសេដ្ឋកិច្ច ដែលជាសត្រូវរបស់ប្រទេសគេនេះឯង ។ ត្រង់បញ្ហានេះ យើងនឹកឃើញសោកនាដកម្មខ្មែរអស់រយៈពេល៣០ឆ្នាំ គឺបណ្តាលមកពីខ្មែរពេលនោះប្រគល់ដីឲ្យយៀកកុង-យៀកណាមខាងជើងប្រើប្រាស់ដាក់មូលដ្ឋានទ័ព បណ្តាលឲ្យសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកក្នុងសិទ្ធិដេញតាមសត្រូវ កើតការទម្លាក់គ្នាថ្ងៃ១៨មីនា ១៩៧០ កើតមានវាលពិឃាតជាដើម មានមូលហេតុកើតពីការគាំទ្រសត្រូវរបស់គេនេះឯង ។ ដូច្នេះរាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ននេះទោះបីចង់ឬមិនចង់ ត្រូវតែទទួលខុសត្រូវចំពោះបញ្ហាជាតិ ដោយសារនយោបាយរបស់រាជរដ្ឋាភិបាលខ្មែរកំពុងដើរផ្លូវមួយប្រកបដោយគ្រោះថ្នាក់ ។ បើស្ថានការណ៍នេះដើររហូតដល់ខ្មែរនិងថៃធ្វើសង្គ្រាមនឹងគ្នា ទោះបីពឹងកម្លាំងទ័ពយួនក៏ដោយ ខ្មែរនឹងត្រូវវិនាសទាំងសម្បត្តិនិងជីវិតមនុស្សសាជាថ្មី ហើយពេលនោះយួននឹងត្រួតត្រាប្រទេសកម្ពុជាដូចនៅលាវ ព្រោះខ្មែរនៅខ្សោយមិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីទប់ទល់នឹងទ័ពសៀម នេះជាចំណងរបស់វៀតណាមក្នុងផែនការសហព័ន្ធឥណ្ឌូចិនរបស់ខ្មោចហូ-ជីមិញ ។ ប៉ុន្តែបើរាជរដ្ឋាភិបាលខ្មែររកមធ្យោបាយបញ្ចៀសសង្គ្រាមបាន ដោយមិនប្រើកម្លាំងបាយខ្ពស់កប់ពពកមកជ្រកអាចម៍ជន្លេន យើងសូមអនុមោទនាទទួលសាធុប្រែថាល្អហើយប្រពៃហើយ ។ យើងឮពត៌មានថា រាជរដ្ឋាភិបាលខ្មែរចោទលោកសម-រង្ស៊ីជាប្រធានគណបក្សប្រឆាំងថា លោកសម-រង្ស៊ីជាជនក្បត់ជាតិ ព្រោះគាំទ្រលោកអាភីស៊ិតនាយករដ្ឋមន្ត្រីថៃបច្ចុប្បន្ន ដោយលោកសម-រង្ស៊ីមានសំដីដូចលោកអាភីស៊ិតថា បញ្ហាកាត់ទោសលោកស៊ីវ៉ារ៉ាក់ និងការលើកលែងទោសជាឆាកល្ខោនរបស់រដ្ឋាភិបាលខ្មែរ ។ យើងលើកយកពាក្យក្បត់ជាតិមកពិចារណា យើងចាត់ថាលោកសម-រង្ស៊ីគាំទ្រលោកអាភីស៊ិតតាមពាក្យចោទនោះទៅចុះ តើលោកអាភីស៊ិតជានរណា គឺនាយករដ្ឋមន្ត្រីកាន់អំណាចបច្ចុប្បន្ន យើងមិននិយាយថាគេកាន់អំណាចរបៀបណាក៏ដោយ ជាស្វ័យសំរេចរបស់គេ ចុះរាជរដ្ឋាភិបាលខ្មែរទទួលស្គាល់អ្នកណាជាតំណាងប្រទេសថៃ បើមានកិច្ចការជាមួយខ្មែរ និយាយជាមួយអ្នកណា បើនិយាយជាមួយថាក់ស៊ីនជាជនអស់អំណាចគ្មានតំណាងប្រទេសថៃ តើមានប្រយោជន៍អី ? ដូច្នេះតើរវាងលោកសម-រង្ស៊ីនិងរាជរដ្ឋាភិបាលខ្មែរទាំងពីរនេះ អ្នកណាក្បត់ជាតិ អ្នកណាស្រឡាញ់ជាតិ ? ពាក្យថាឆាកល្ខោនឬមិនឆាកល្ខោននោះ សូមពិចារណាតាមពាក្យដែលបានធ្វើវិភាគមកហើយ ។

យើងបានឃើញដីកាបង្គាប់ឲ្យចូលខ្លួន ដែលចេញដោយលោកឡុង-កេសភីរម្យ ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តស្វាយរៀង ចោទលោកសម-រង្ស៊ីថា ធ្វើឲ្យខូចខាតដោយចេតនា (គាស់បង្គោលព្រំដែនលេខ១៨៥) និងការញុះញង់ឲ្យមានការរើសអើងជាតិសាសន៍ ។ យើងសាកល្បងពិចារណាមើលពាក្យចោទនោះ តើសមហេតុសមផលឬទេ ? ការចោទលោកសម-រង្ស៊ីអំពីការដកបង្គោលឈើតូចៗ៦កំណាត់ ជារបៀបឈើអុសដុតគ្រាន់តែដោតតំរុយ បើនៅបរទេសគ្មានតម្លៃអ្វីឡើ-យ បើលក់គ្មានអ្នកទិញយកទៅធ្វើអ្វីដែរ, យើងស្មានបើនៅប្រទេសកម្ពុជា បើគេឲ្យសងមិនលើសពីពីរឬបីដុល្លារប៉ុណ្ណោះ ។ បើខូចខាតប៉ុណ្ណោះ មានទោសរហូតដល់ដកអភ័យឯកសិទ្ធិ រហូតឡើងតុលាការចោទជាបទព្រហ្មទណ្ឌអន្តរកាល ។ ពាក្យចោទថា «ញុះញង់ឲ្យមានការរើសអើងជាតិសាសន៍» ។ យើងមិនយល់អំពីសំនេររបស់ចៅក្រមសាលាដំបូង ដែលធ្វើតាមបញ្ជាថ្នាក់លើអំពីការរើសអើងនេះ មិនដឹងជាមានន័យថាបែបណាទេ ចំពោះការចោទលោកសម-រង្ស៊ីនេះ ។ សូមសួរថា ថៃមករំលោភយកដីខ្មែរនៅជុំវិញប្រាសាទព្រះវិហារ ពលរដ្ឋខ្មែរប្រឆាំងនឹងការរំលោភនោះ តើត្រូវចោទពលរដ្ឋខ្មែរថារើសអើងជាតិសាសន៍ថៃយ៉ាងហ្នឹងឬ ? ចោរមកប្លន់ទ្រព្យសម្បត្តិ ម្ចាស់ទ្រព្យសម្បត្តិប្រឆាំងនឹងចោរ តើត្រូវចោទម្ចាស់ទ្រព្យថា រើសអើងចោរយ៉ាងហ្នឹងឬ ? យ៉ាងណាមិញ ដីជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ជាកម្មសិទ្ធិឯកជន បើមានគេមកបោះបង្គោលនៅលើដីរបស់ខ្លួន ត្រូវតែដកចោល នេះជាអំពើសមហេតុផល ។ បើអាជ្ញាធរខ្មែរបោះបង្គោលនោះជាមួយវៀតណាមវិញ ដោយមិនបានប្រាប់ម្ចាស់ដី ជាការរំលោភសកម្មសិទ្ធិឯកជនរបស់រដ្ឋ ត្រូវមានកំហុស បើធ្វើឲ្យបាត់បង់ដីពលរដ្ឋទៀត ត្រូវតែប្តឹងអំពីបទដែលធ្វើឲ្យបាត់បង់ដីរបស់ខ្លួន នេះជាសមភាពចំពោះមុខច្បាប់ ពុំមែនរដ្ឋចេះតែធ្វើអ្វីបានតាមចិត្តនោះទេ ចំ-ពោះរបបដែលពុំមែនជាកុម្មុយនិស្ត ។ ចំពោះលោកសម-រង្ស៊ីដែលចូលរួមក្នុងការដកនេះ តាមមុខងាររបស់តំណាងរាស្ត្រ ត្រូវចុះសួរសុខទុក្ខរាស្ត្រ ជួយដោះស្រាយបញ្ហារាស្ត្រ ទំនងជាមើលឃើញការយំស្រែករបស់ប្រជារាស្ត្រ ដែលពោលថាដីស្រែរបស់ខ្លួនបានត្រូវបាត់បង់ ឥឡូវបង្គោលតម្រុយនេះទំនងជាគេកាត់យកទៀតហើយ ដូច្នេះត្រូវដកចោលតែម្តងទៅ ។

មានអ្នកធ្វើវិភាគនយោបាយនៅក្នុងកញ្ចក់ទូរទស្សន៍ដែលគាំទ្ររាជរដ្ឋាភិបាលនៅភ្នំពេញ សុទ្ធតែថ្នាក់បណ្ឌិតមិនដឹងជាបណ្ឌិតបានមកពីប្រទេសណាទេ វិភាគនោះហៃអើជ្រុលពេក ចោទលោកសម-រង្ស៊ីដែលដកបង្គោលនោះថាជនក្បត់ជាតិ ។ ចុះខ្លួនហៃអើឲ្យយួនបោះចូលមកដីស្រែរបស់រាស្ត្រខ្មែរនោះវិញ ខ្លួនក្បត់អីដែរ ? គេចោទទៀតថា អំពើរបស់លោកសម-រង្ស៊ីនេះ បើក្នុងសមរភូមិចាត់ទុកថាបំបែកកម្លាំង ព្រោះកំពុងប្រយុទ្ធជាមួយសៀម លោកសម-រង្ស៊ីបង្កើតបញ្ហានេះឡើងនៅទិសខាងកើត ។ យើងសូមលើកយកឧទាហរណ៍មួយមកសួរថា មានបុរសម្នាក់មានកូនពីរនាក់ ក្នុងពេលជាមួយគ្នាកូនម្នាក់មានជម្ងឺជាទម្ងន់នៅផ្ទះ កូនម្នាក់ទៀតត្រូវគ្រោះថ្នាក់ចរាចរសន្លប់បាត់ស្មារតី តើបុរសជាឪពុកត្រូវដោះស្រាយជួយសង្គ្រោះកូនទាំងពីរ ឬដោះស្រាយតែកូនណាមួយ ? យ៉ាងណាមិញ កំពុងដោះស្រាយបញ្ហាថៃនៅទិសខាងលិច នៅពេលជាមួយគ្នានោះ ពលរដ្ឋខ្មែរនៅស្រុកចន្ទ្រា ខេត្តស្វាយរៀងយំស្រែកថា ខ្លួនបានបាត់បង់ដីស្រែរបស់ខ្លួន តើតំណាងរាស្ត្រដែលជាតំណាងរបស់រាស្ត្រត្រូវដោះស្រាយអំពីសុខទុក្ខរបស់រាស្ត្រនោះ ត្រូវប្រតិបត្តិបែបណាដែរ ? ត្រូវនៅស្ទៀមចាំដោះស្រាយបញ្ហាព្រំដែនរវាងខ្មែរនិងថៃឲ្យរួចស្រេចបាច់សិន ចាំដោះស្រាយដីស្រែរបស់ពលរដ្ឋដែលបាត់បង់ជាក្រោយ

យ៉ាងហ្នឹងឬ ? ការវិភាគនេះពុំមែនកាន់ជើងខាងណាទេ ប៉ុន្តែចង់ឲ្យរដ្ឋប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ ទើបមានស្ថេរភាពខាងនយោបាយ ។

ពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេសមានការបារម្ភបាត់បង់ទឹកដីខ្មែរ តាំងពីវៀតណាមចូលមកត្រួតត្រាលើប្រទេសកម្ពុជា រហូតមានសន្ធិសញ្ញារវាងខ្មែរនិងវៀតណាម ដែលមានភាពមិនស្មើគ្នា ។ សន្ធិសញ្ញានេះមិនត្រឹមតែពុំព្រមលុបតាមកិច្ចព្រមព្រៀងសន្តិភាពនៅប្រទេសបារាំងឆ្នាំ១៩៩១ទេ ថែមទាំងធ្វើស្របច្បាប់ទៀត ។ តើក្នុងអំឡុងពេលដែលវៀតណាមចូលមកត្រួតត្រាលើប្រទេសកម្ពុជា ខ្មែរត្រូវបាត់បង់ទឹកដីអស់ប៉ុន្មាន ? បច្ចុប្បន្ននេះ នៅស្រុកចន្ទ្រាខេត្តស្វាយរៀងតែមួយត្រូវគេបោះបង្គោលចូលមកដីខ្មែរជាច្រើនគីឡូម៉ែត្រ ចុះកន្លែងដទៃទៀតនៅតាមព្រំដែនរាប់រយគីឡូម៉ែត្រ ត្រូវបាត់បង់ទឹកដីប៉ុន្មានគីឡូម៉ែត្រទៀត ។ អាជ្ញាធរខ្មែរអះអាងថា ធម្មតាផែនទីវាស់លើដីជាក់ស្តែង តែងចូលទៅខាងដីម្ខាងៗខ្លះពុំខាន ។ តាមពិតគេវាស់ចូលមកតែដីខ្មែរ បើមានចូលដីវៀតណាមវិញ ដូចម្តេចបានជាវៀតណាមមិនព្រួសូរស្រែកថាបាត់បង់ទឹកដីដូចពលរដ្ឋខ្មែរ ។ បើវាស់អាចខុសត្រូវបន្តិចបន្តួច ដោយសារកន្លែងទឹកស្ទឹងឬទន្លេមានដីបាក់ បើចូលមកដីខ្មែររាប់គីឡូម៉ែត្រដូច្នេះ ពុំអាចថាត្រឹមត្រូវយកជាការបានឡើយ ។ ផែនទីដែលបារាំងគូររបស់ប្រទេសនៅឥណ្ឌូចិន (ខ្មែរ-វៀតណាម-លាវ) មុនឆ្នាំ១៩៥៣ ហើយយកទៅដឹកល់នៅសហប្រជាជាតិនៅឆ្នាំ១៩៦៤ អាចទុកជាផែនទីមូលដ្ឋានជាផ្លូវការ ។ ចំណែកផែនទីដែលវៀតណាមគូរថ្មី តាមសន្ធិសញ្ញាឆ្នាំ១៩៨៥ ពុំអាចយកជាការបានឡើយ អាចធ្វើឲ្យខ្មែរបាត់បង់ទឹកដីរបស់ខ្លួន ។៚

❊ ❊

❊